ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

## អនាគតនៃ
# ទីផ្សារការងារកម្ពុជា



## ព្រឹត្តិបត្រព័ត៌មានទីផ្សារការងារ

# ការបណ្តុះបណ្តាលក្នុង
# វិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

ឆ្នាំទី ១
លេខ ២

# អារម្ភកថា

ចាប់តាំងពីដើមឆ្នាំ២០២០ រហូតដល់ពាក់កណ្តាលឆ្នាំ២០២១ នេះ កម្ពុជា ក៏ដូចជាបណ្តាប្រទេសលើពិភពលោក បាននិងកំពុងទទួលរងនូវផលប៉ះពាល់អវិជ្ជមាននៃជំងឺរាតត្បាតជាសកលកូវីដ-១៩ មកលើបញ្ហាសុខភាពសាធារណៈ សេដ្ឋកិច្ចសង្គម ការអប់រំនិងបណ្តុះបណ្តាល និងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ការបាត់បង់ការងារនិងប្រាក់ចំណូល ហើយថែមទាំងបន្ថយបង្អាក់ដល់ការអភិវឌ្ឍឈានឡើងរបស់កម្ពុជាផងដែរ។ គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅទូទាំងប្រទេសទាំងសាធារណៈ ឯកជន និងអង្គការ សមាគម ត្រូវបានផ្អាកដំណើរការបណ្តុះបណ្តាល និងសកម្មភាពនានាជាបន្តបន្ទាប់ទៅតាមដំណាក់កាលនៃការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩។ ដើម្បីធានានិរន្តភាពនៃការបង្រៀន និងរៀនរបស់សាស្ត្រាចារ្យ គ្រូបច្ចេកទេស និងសិក្ខាកាម សិស្ស និស្សិត ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដាក់ចេញនូវគោលការណ៍ណែនាំស្តីពីការបង្រៀន និងរៀនពីចម្ងាយ ឬតាមអនឡាញ សម្រាប់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងបាននិងកំពុងដាក់ឱ្យដំណើរការប្រព័ន្ធជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈពីចម្ងាយ ឬតាមអនឡាញ ព្រមទាំងបំពាក់មូលដ្ឋានសម្ភារ ឧបករណ៍បច្ចេកវិទ្យាព័ត៌មាន ក៏ដូចជាការអភិវឌ្ឍន៍និងកែលម្អកម្មវិធីសិក្សា និងបំប៉នសមត្ថភាពគ្រូបច្ចេកទេសនូវវិធីសាស្ត្របង្រៀនបែបគន្លងថ្មីសម្រាប់គាំទ្រដល់ការបង្រៀន និងរៀនពីចម្ងាយ ឬតាមអនឡាញ នៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។

ព្រឹត្តិបត្រព័ត៌មានទីផ្សារការងារលេខ ២ នេះ នឹងចូលរួមចំណែកជាមគ្គុទ្ទេសក៍ និងត្រីវិស័យសម្រាប់តម្រង់ទិសដល់យុវជនក្នុងការសម្រេចចិត្តជ្រើសរើសជំនាញសិក្សា និងត្រៀមខ្លួនចូលទៅកាន់ទីផ្សារការងារនាពេលអនាគត។ សៀវភៅនេះបានបង្ហាញឱ្យឃើញពីស្ថានភាពទូទៅនៃទីផ្សារការងារ និងការព្យាករណ៍ពីតម្រូវការអ្នកបច្ចេកទេសក្នុងទីផ្សារការងារ និងជំនាញកំពុងធ្វើការបណ្តុះបណ្តាលក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។

នាយកដ្ឋានព័ត៌មានទីផ្សារការងារ នៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានខិតខំសិក្សាស្រាវជ្រាវ និងចងក្រងព្រឹត្តិបត្រព័ត៌មានទីផ្សារការងារនេះឡើង ដើម្បីជាប្រយោជន៍ដល់សាធារណជនទូទៅ ជាពិសេសយុវជនអាចឈ្វេងយល់ព័ត៌មានអំពីជំនាញបច្ចេកទេស និងវិជ្ជាជីវៈ និងតម្រូវការកម្លាំងពលកម្មនៅលើទីផ្សារការងារ បង្កើនភាពងាយស្រួលដល់ការចាប់យកជំនាញវិជ្ជាជីវៈរបស់យុវជន និងឱកាសទទួលបានការងារស្របតាមតម្រូវការទីផ្សារការងារក្នុង និងក្រៅប្រទេស។

# ព្រឹត្តិបត្រព័ត៌មានទីផ្សារការងារ

**គណៈគ្រប់គ្រង**
ឯកឧត្តមបណ្ឌិត ពេជ សោភ័ន
ឯកឧត្តម ប៉ុក ប៉ាន់
ឯកឧត្តម ឡៅ ហ៊ីម
ឯកឧត្តម ទេព ណារី
ឯកឧត្តម ហ៊ីង ស៊ីដេត

**នាយកគ្រប់គ្រងទូទៅ**
ឯកឧត្តម ថង សាម៉ុន

**នាយកនិពន្ធ**
លោកស្រី សៅ សុគន្ធកេត្យា

**នាយករងនិពន្ធ**
លោក យស ធីរិទ្ធ
លោក ចាន់ សារុធ
លោក ងួន ភុនពិសី
លោក គិត សុភាព
លោក ឈាង ចន្ទា

**ការីនិពន្ធ និងអ្នករចនាអត្ថបទ**
លោក ងួន ភុនពិសី
លោក ភួង រ័ត្នសុធា
លោ ទេព សេងហ៊ន
លោក សុខ ធម្មភាសី
លោក ភឿន ផារី

**ផ្នែករូបភាព និងកុំព្យូទ័រ**
លោក គិត សុភាព
លោក ឈាង ចន្ទា
លោក កុល សុខត័ង
លោក ប៊ុនធឿន អរុណរតនៈ

**ផ្នែកពិនិត្យ និងកែសម្រួលអក្ខរាវិរុទ្ធ**
លោក យស ធីរិទ្ធ
លោក ចាន់ សារុធ
លោកស្រី លី សុខសម្បត្តិ
លោក សាយ ស៊ីមាន
លោក គន់ កាន់ណា

## មាតិកា


អារម្ភកថា.......................................i
បញ្ជីរូបភាព និងតារាង..........................iii
អក្សរកាត់......................................iV

I. ស្ថានភាពទូទៅនៃទីផ្សារការងារកម្ពុជា.............១
១-ចំនួនប្រជាជនតាមអាយុ..............................១
២-កម្រិតសិក្សាអប់រំ..................................២
៣-កម្លាំងពលកម្មនៅកម្ពុជា.............................៣
៤-សកម្មជនសេដ្ឋកិច្ច និងកម្លាំងពលកម្ម................៥

II. ការព្យាករណ៍ពីតម្រូវការអ្នកបច្ចេកទេស ក្នុងទីផ្សារការងារ.............................................៦

III. ការបណ្តុះបណ្តាលក្នុងវិស័យអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ......១០
១-លំហូរនៃការចូលរៀនក្នុងវិស័យអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ...........១០
២-ស្ថិតិសិក្ខាកាម សិស្ស និស្សិតសិក្សាតាម ជំនាញអាទិភាព ឆ្នាំសិក្សា២០១៩-២០២០.....១២
៣-កម្មវិធីបង្រៀន និងរៀនពីចម្ងាយ ឬតាមអនឡាញ.........................................១២
៤-កម្មវិធីបណ្តុះបណ្តាលកម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ១(C1)វគ្គពិសេសជូនកម្មករនិយោជិត......១៤
៥-និមិត្តសញ្ញា អ.ប.វ. (TVET Cambodia)..........១៥

ឯកសារយោង.....................................១៧

# បញ្ជីរូបភាព និងតារាង

## ក. បញ្ជីរូបភាព


រូបភាពទី១៖ ប្រជាជនសរុបឆ្នាំ២០១៩ ........ ១
រូបភាពទី២៖ ចំនួនប្រជាជនសរុបតាមរាជធានី ខេត្ត ឆ្នាំ២០១៩........ ១
រូបភាពទី៣៖ ប្រៀបធៀបកម្លាំងពលកម្មតាមអាយុឆ្នាំ២០០៨-២០១៩........ ២
រូបភាពទី៤៖ ភាគរយប្រជាជនអក្ខរភាពអាយុ ៧ឆ្នាំតាមកម្រិតសិក្សាអប់រំ កម្ពុជា ឆ្នាំ២០០៨-២០១៩........ ២
រូបភាពទី៥៖ កម្លាំងពលកម្មតាមអាយុឆ្នាំ២០១៩........ ៣
រូបភាពទី៦៖ ប្រៀបធៀបកម្លាំងពលកម្មតាមវិស័យឆ្នាំ២០០៨ និងឆ្នាំ២០១៩ ........ ៤
រូបភាពទី៧៖ កម្លាំងពលកម្មតាមវិស័យឆ្នាំ២០១៧-២០២២ ........ ៤
រូបភាពទី៨៖ ស្ថានភាពសកម្មភាពសេដ្ឋកិច្ចអាយុ ៥ឆ្នាំឡើង តាមភេទ និងតំបន់កម្ពុជា ឆ្នាំ២០០៨-២០១៩........ ៥
រូបភាពទី៩៖ ភាគរយអក្ខរភាពអាយុ ៧ឆ្នាំឡើង តាមភេទ កម្ពុជា ឆ្នាំ២០០៨-២០១៩....... ១០
រូបភាពទី១០៖ ស្ថិតិសិក្ខាកាម សិស្ស និស្សិត បញ្ចប់ការសិក្សាពីឆ្នាំ២០០៥-២០២០........ ១១
រូបភាពទី១១៖ ស្ថិតិសិក្ខាកាម សិស្ស និស្សិត បញ្ចប់ការសិក្សាពីឆ្នាំ២០០៥-២០២០ របស់គ្រឹះស្ថាន អ.ប.វ. សាធារណៈ ........ ១១
រូបភាពទី១២៖ ស្ថិតិសិក្ខាកាម សិស្ស និស្សិតតាមវិស័យឆ្នាំសិក្សា ២០១៤-២០២០ ........ ១២
រូបភាពទី១៣៖ សិក្ខាកាមទទួលបានការបណ្តុះបណ្តាល C1 វគ្គពិសេស........ ១៤


## ខ. បញ្ជីតារាង


តារាងទី១៖ អ្នកមានការងារធ្វើនៅកម្ពុជាតាមផ្នែក ឆ្នាំ២០០៨ និងឆ្នាំ២០១៩ ........ ៤
តារាងទី២៖ ស្ថិតិកម្លាំងពលកម្មតាមវិស័យ (កសិកម្ម ឧស្សាហកម្ម និងសេវាកម្ម) ឆ្នាំ២០១៧-២០២២........ ៥
តារាងទី៣៖ អត្រាអ្នកចូលរួមកម្លាំងពលកម្មអាយុជាក់លាក់ (ភាគរយ) តាមក្រុមអាយុ ភេទ និងតំបន់ កម្ពុជា ឆ្នាំ២០០៨-២០១៩........ ៦
តារាងទី៤៖ ចំនួនអ្នកដែលចូលក្នុងវិស័យការងារតាមមុខរបរសំខាន់ៗ តម្លៃដាច់ខាត (គិតជាពាន់) និងសមាសភាពជា% ឆ្នាំ២០១៧-២០២២........ ៧
តារាងទី៥៖ តម្រូវការកម្លាំងពលកម្មជាមធ្យមប្រចាំឆ្នាំក្នុងលក្ខខណ្ឌលំហូរ Macro-occupations (ឆ្នាំ២០១៨-២០២២) បញ្ជីមុខរបរសម្រាប់វគ្គបណ្តុះបណ្តាលដែលត្រូវការ ដើម្បីប្រឈមនឹងកង្វះនៃការផ្គត់ផ្គង់បុគ្គលដែលមានគុណវុឌ្ឍិ និងបញ្ជីមុខរបរដែលបានផ្តល់អនុសាសន៍ដើម្បីធ្វើការបណ្តុះបណ្តាល........ ៩

# អក្សរកាត់

| | | |
|---|---|---|
| អ.ប.វ. | = | អប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ |
| TVET | = | Technical Vocational Education and Training |
| TVETSDP | = | Technical Vocational Education and Training Sector Development Project |
| NEA | = | National Employment Agency |
| JOI | = | Job Outlook Index |
| TVETMIS | = | Technical Vocational Education and Training Management Information System |
| ICT | = | Informational Communication Technology |
| PPI | = | Preah Kossomak Polytechnic Institute |
| NIEI | = | National Institute of Entrepreneurship and Innovation |
| NIB | = | National Institute of Business |
| ITI | = | Industrial Technical Institute |
| RPITSVR | = | Regional Polytechnic Institute Techo Sen Svay Rieng |
| RPITSSR | = | Regional Polytechnic Institute Techo Sen Siem Reap |
| NPIA | = | National Polytechnic Institute of Angkor |
| PIPK | = | Polytechnic Institute Kampong Cham Province |
| PIP | = | Polytechnic Institute of Preah Sihanouk |
| PCCFPI | = | Preah Sihanouk Cambodia Chinese Friendship Polytechnic Institute |
| NVIB | = | National Vocation Institute of Battambang |
| PIPP | = | Polytechnic Institute of Pursat Province |
| PIBMC | = | Polytechnic Institute of Banteay Meanchey Province |
| KDPTC | = | Kandal Provincial Training Center |
| KCHHPTC | = | Kampong Chhnang Provincial Training Center |

# I. ស្ថានភាពទូទៅនៃទីផ្សារការងារកម្ពុជា

## ១-ចំនួនប្រជាជនតាមអាយុ

លទ្ធផលចុងក្រោយនៃជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ បង្ហាញថា ប្រជាជនសរុបតាមវិធីសាស្ត្រឃើញរាប់ តាមពេលវេលាយោងម៉ោងសូន្យ ថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៩ មានចំនួន ១៥ ៥៥២ ២១១នាក់ បានកើនឡើងពី ១៣ ៣៩៥ ៦៨២នាក់ នៅឆ្នាំ២០០៨។ ចំនួនប្រជាជនសរុបកើនឡើង ២ ១៥៦ ៥២៩នាក់ ត្រូវជា ១៦,១% ក្នុងរយៈពេល ១១ឆ្នាំ (២០០៨ ទៅ ២០១៩)។ ចំនួនប្រុសមាន ៧ ៥៧១ ៨៣៧នាក់ ស្មើនឹង ៤៨,៧% នៃចំនួនប្រជាជនកម្ពុជាសរុប ខណៈពេលដែលចំនួនស្ត្រីមាន ៧ ៩៨០ ៣៧៤នាក់ ស្មើនឹង ៥១,៣% នៃចំនួនប្រជាជនកម្ពុជាសរុប។




*រូបភាពទី១៖ ប្រជាជនសរុបឆ្នាំ២០១៩*




*រូបភាពទី២៖ ចំនួនប្រជាជនសរុបតាមរាជធានី ខេត្ត ឆ្នាំ២០១៩*

ចំនួនប្រជាជនសរុបបែងចែកតាមអាយុក្នុងឆ្នាំ២០១៩ គិតជាភាគរយ ១០០% ស្មើនឹងប្រជាជនសរុបចំនួន ១៥ ៥៥២ ២១១នាក់ បែងចែកតាមអាយុជា ៣ក្រុម គិតជាភាគរយ រួមមាន៖

ក. ប្រជាជនដែលមានអាយុ ០ ឆ្នាំ ទៅដល់អាយុ ១៤ឆ្នាំ មានចំនួន ៣៣,៧% ស្មើនឹងចំនួនប្រជាជនប្រមាណ ៥ ២៤១ ០៩២នាក់

ខ. ប្រជាជនដែលមានអាយុ ១៥ ឆ្នាំ ទៅដល់អាយុ ៥៩ឆ្នាំ មានចំនួន ៦០,០% ស្មើនឹងចំនួនប្រជាជន ប្រមាណ ៩ ៣៣១ ៣២៧នាក់

គ. ប្រជាជនដែលមានអាយុ ៦០ឆ្នាំ ឡើងទៅមានចំនួន ៦,៣% ស្មើនឹងចំនួនប្រជាជនប្រមាណ ៩៧៩ ៧៨៩នាក់។

ដូចនេះ បើយោងលើទិន្នន័យដែលបានបង្ហាញខាងលើយើងឃើញថា កម្ពុជាមានចំនួនប្រជាជនកើនឡើងជារៀងរាល់ឆ្នាំ និងចំនួនប្រជាជនដែលមានអាយុត្រូវចូលក្នុងទីផ្សារការងារក៏កើនឡើងជារៀងរាល់ឆ្នាំផងដែរ[9]។

*រូបភាពទី៣៖ ប្រៀបធៀបកម្លាំងពលកម្មតាមអាយុឆ្នាំ២០០៨-២០១៩*




[9] *ប្រភព៖ សៀវភៅជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩*

## ២-កម្រិតសិក្សាអប់រំ

កម្រិតអប់រំ គឺជាសូចនាករសំខាន់មួយនៃគុណភាពប្រជាជន។ នៅកម្រិតថ្នាក់ជាតិ លទ្ធផលជំរឿនឆ្នាំ២០១៩ បង្ហាញថា ២៩,១ % នៃប្រជាជនអាយុ ៧ឆ្នាំឡើងដែលធ្លាប់បានចូលរៀននៅសាលា ឬគ្រឹះស្ថានសិក្សាណាមួយបានបញ្ចប់ថ្នាក់បឋមសិក្សាហើយ ២១,៨% បានបញ្ចប់ថ្នាក់មធ្យមសិក្សាបឋមភូមិមាន ២,៩% បានបញ្ចប់មធ្យមសិក្សា/មានសញ្ញាបត្រមធ្យមសិក្សា

*រូបភាពទី៣៖ ភាគរយប្រជាជនអក្ខរភាពអាយុ ៧ឆ្នាំតាមកម្រិតសិក្សាអប់រំ កម្ពុជា ឆ្នាំ២០០៨-២០១៩*



ទុតិយភូមិ (សញ្ញាបត្រមធ្យមសិក្សាបឋមភូមិមានបច្ចេកទេស/វិជ្ជាជីវៈសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមានបច្ចេកទេស/វិជ្ជាជីវៈ) និងបានបញ្ចប់ក្រោយមធ្យមសិក្សា (សញ្ញាបត្រថ្នាក់មហាវិទ្យាល័យ សញ្ញាបត្រថ្នាក់អនុបណ្ឌិត និងសញ្ញាបត្រថ្នាក់បណ្ឌិត) មានតែ ២,៨%។ មានប្រមាណ ៤២,៣% នៃប្រជាជនកម្ពុជាអាយុ ៧ឆ្នាំឡើង មិនបានបញ្ចប់ថ្នាក់បឋមសិក្សា ខណៈដែលមានសមាមាត្រតិច (១,១%) នៃប្រជាជនអក្ខរភាពមិនបានបញ្ចប់ថ្នាក់ណាមួយ។ ប្រៀបធៀបនឹងជំរឿនឆ្នាំ២០០៨ មានការកែលម្អផ្នែកកម្រិតសិក្សាអប់រំក្នុងចំណោមប្រជាជនអក្ខរភាព។ លទ្ធផលបង្ហាញថា សមាមាត្របានថយចុះក្នុងចំណោមប្រជាជនមិនបានបញ្ចប់ថ្នាក់បឋមសិក្សាមានភាគរយខុសគ្នាបន្តិច។ រីឯបញ្ចប់ថ្នាក់មធ្យមសិក្សាបឋមភូមិបានកើនឡើងពី ១៧,០% ទៅ ២១,៨% ខណៈដែលបានបញ្ចប់មធ្យមសិក្សា/មានសញ្ញាបត្រ (បានបញ្ចប់មធ្យមសិក្សា/មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សញ្ញាបត្រមធ្យមសិក្សាបឋមភូមិមានបច្ចេកទេស/វិជ្ជាជីវៈ សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមានបច្ចេកទេស/វិជ្ជាជីវៈ) បានកើនឡើងពី ១,៦% ទៅ ២,៩% និងបានបញ្ចប់ក្រោយមធ្យមសិក្សា (សញ្ញាបត្រ ថ្នាក់មហាវិទ្យាល័យ សញ្ញាបត្រថ្នាក់អនុបណ្ឌិត និងសញ្ញាបត្រថ្នាក់បណ្ឌិត) កើនពី ១,៥% ទៅ ២,៨% ផងដែរ[២]។

[២] *ប្រភព៖ សៀវភៅជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩*

## ៣-កម្លាំងពលកម្មនៅកម្ពុជា

យោងតាមការសិក្សាស្រាវជ្រាវកន្លងមកបានបង្ហាញថា ព្រះរាជាណាចក្រកម្ពុជាមានកម្លាំងពលកម្មចំនួន ៦ ៩៣៤ ៧៥៩នាក់ ក្នុងឆ្នាំ ២០០៨ និងកម្លាំងពលកម្មចំនួន ៨ ៦២៦ ៧៧៧ នាក់ ក្នុងឆ្នាំ២០១៩។ បើគិតតាមអាយុកម្ពុជាមានកម្លាំងពលកម្មក្នុងឆ្នាំ២០១៨ ចំនួន ៩៣ ៩៦៤នាក់ អាយុក្រោម ១៥ឆ្នាំ និងកម្លាំងពលកម្មចំនួន ៦ ៣១៤ ៥៦៨នាក់ ដែលមានអាយុចាប់ពី ១៥ឆ្នាំ ឡើងទៅដល់អាយុ ៥៩ឆ្នាំ និងកម្លាំងពលកម្មចំនួន ៥២៦ ២២៧នាក់ អាយុ ៦០ឆ្នាំឡើង។ មួយវិញទៀតទិន្នន័យបានបង្ហាញដែរថា កម្លាំងពលកម្មនៅកម្ពុជាក្នុងឆ្នាំ២០១៩ មានចំនួន ៥៦ ៨៤៥នាក់ ក្រោម អាយុ១៥ឆ្នាំ និងកម្លាំងពលកម្មចំនួន ៧ ៧៥៤ ៣៧២នាក់ ដែលមានអាយុចាប់ពី១៥ឆ្នាំ ឡើងទៅដល់អាយុ ៥៩ឆ្នាំ និងកម្លាំងពលកម្មចំនួន ៨១២ ៥៦០នាក់ អាយុ ៦០ឆ្នាំឡើង។

*រូបភាពទី៥៖ កម្លាំងពលកម្មតាមអាយុឆ្នាំ២០១៩*




កម្លាំងពលកម្មមានន័យថា អ្នកដែលមានការងារធ្វើ ប្រជាជនដែលមានការងារធ្វើ សរុបក្នុងឆ្នាំ២០១៩ មានចំនួន ៨ ៦២៦ ៧៧៧នាក់ បានកើនឡើងប្រមាណ ៩,៤% ក្នុងរយៈពេល ១១ឆ្នាំ ស្មើនឹងចំនួនប្រជាជនប្រមាណ ១ ៦៩២ ០២៤នាក់ នេះបើធៀបទៅនឹងចំនួនប្រជាជនដែលមានការងារធ្វើក្នុងឆ្នាំ២០០៨ ដែលមានចំនួន

៦ ៩៣៤ ៧៥៩នាក់។ កម្លាំងពលកម្ម ឬអ្នកមានការងារធ្វើនៅកម្ពុជាបែងចែកតាមផ្នែក ៨ រួមមាន *(ដូចមានក្នុងតារាងទី១)*៖

*តារាងទី១៖ អ្នកមានការងារធ្វើនៅកម្ពុជាតាមផ្នែក ឆ្នាំ២០០៨ និងឆ្នាំ២០១៩*

| ល.រ | បរិយាយ | ឆ្នាំ២០០៨ | ឆ្នាំ២០១៩ |
|---|---|---|---|
| ១ | រដ្ឋបាល | ៣០៥ ១២៩នាក់ ស្មើនឹង ៤,៤% | ៤២២ ៧១២នាក់ ស្មើនឹង ៤,៩% |
| ២ | សហគ្រាសរដ្ឋ | ២០ ៨០៤នាក់ ស្មើនឹង ០,៣% | ៤៣ ១៣៤នាក់ ស្មើនឹង ០,៥% |
| ៣ | សហគ្រាសឯកជនកម្ពុជា | ៦ ២៦២ ០៨៧នាក់ ស្មើនឹង ៩០,៣% | ៦ ៧៨៩ ២៧៣នាក់ ស្មើនឹង ៧៨,៧% |
| ៤ | សហគ្រាសបរទេស | ៣០៥ ១២៩នាក់ ស្មើនឹង ៤,៤% | ១ ១០៤ ២២៧នាក់ ស្មើនឹង ១២,៨% |
| ៥ | ស្ថាប័នមិនយកប្រាក់ចំណេញ | ៦ ៩៣៥នាក់ ស្មើនឹង ០,១% | ៤៣ ១៣៤នាក់ ស្មើនឹង ០,៥% |
| ៦ | ផ្នែកគ្រួសារ | ២០ ៨០៤នាក់ ស្មើនឹង ០,៣% | ២១៥ ៦៦៩នាក់ ស្មើនឹង ២,៥% |
| ៧ | ស្ថានទូតស្ថាប័នអន្តរជាតិ | ១៣ ៨៧០នាក់ ស្មើនឹង០,២% | ០០នាក់ ស្មើនឹង ០,០% |
| ៨ | ដទៃទៀត | ០០នាក់ ស្មើនឹង ០,០% | ៨ ៦២៧នាក់ ស្មើនឹង ០,១% |

*រូបភាពទី៦៖ ប្រៀបធៀបកម្លាំងពលកម្មតាមវិស័យឆ្នាំ២០០៨ និងឆ្នាំ២០១៩*




*រូបភាពទី៧៖ កម្លាំងពលកម្មតាមវិស័យ ឆ្នាំ២០១៧-២០២២*




ជំរឿនបង្ហាញថា កសិកម្ម គឺជាវិស័យដែលចំណាស់ជាងគេ បន្ទាប់មកសេវាកម្មដែលមានអាយុកាលមធ្យមស្របនឹងចំនួនការងារសរុប និងចុងក្រោយ គឺវិស័យឧស្សាហកម្ម។ ការគិតទុកជាមុនទៅលើកម្លាំងពលកម្មតាមវិស័យ ៣ធំៗខាងលើ ទិន្នន័យបានបង្ហាញថា ប្រទេសកម្ពុជាក្នុងឆ្នាំ២០២១ និងឆ្នាំ២០២២ កម្លាំងពលកម្មក្នុងវិស័យកសិកម្មនឹងធ្លាក់ចុះជាបន្តបន្ទាប់ ប៉ុន្តែកម្លាំងពលកម្មក្នុងវិស័យឧស្សាហកម្មនឹងហក់ឡើងខ្ពស់ជាងគេ ហើយវិស័យសេវាកម្មនឹងឡើងខ្ពស់ជាមធ្យម[៣]។

---

*[៣] ប្រភព៖ សៀវភៅជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩*

*តារាងទី២៖ ស្ថិតិកម្លាំងពលកម្មតាមវិស័យ (កសិកម្ម ឧស្សាហកម្ម និងសេវាកម្ម) ឆ្នាំ២០១៧-២០២២*

| ឆ្នាំ | កម្រិតការងារ | | | សរុប |
|---|---|---|---|---|
| | កសិកម្ម | ឧស្សាហកម្ម | សេវាកម្ម | |
| ២០១៧ | ៣ ២៤៥ | ២ ២៩៨ | ៣ ២២៧ | ៨ ៧៧០ |
| ២០១៨ | ៣ ០៩៦ | ២ ៤៥៨ | ៣ ៣៧០ | ៨ ៩២៤ |
| ២០១៩ | ២ ៩៤១ | ២ ៦២៣ | ៣ ៥១៦ | ៩ ០៨០ |
| ២០២០ | ២ ៧៨០ | ២ ៧៩៣ | ៣ ៦៦៦ | ៩ ២៣៩ |
| ២០២១ | ២ ៧១២ | ២ ៩៦៨ | ៣ ៨២១ | ៩ ៤០១ |
| ២០២២ | ២ ៤៣៧ | ៣ ១៤៨ | ៣ ៩៨០ | ៩ ៥៦៥ |
| ២០១៧-២០២២ | -៨០៨ | ៨៥០ | ៧៥៣ | ៧៩៥ |

## ៤-សកម្មជនសេដ្ឋកិច្ច និងកម្លាំងពលកម្ម

សកម្មជនសេដ្ឋកិច្ចជាផ្នែកមួយនៃកម្លាំងពលកម្មសម្រាប់ផលិតកម្មទំនិញ និងសេវាកម្ម។ ម្យ៉ាងទៀត សកម្មជនសេដ្ឋកិច្ចរាប់បញ្ចូលអ្នកដែលកំពុងធ្វើការបច្ចុប្បន្ន និងអ្នកដែលគ្មានការងារធ្វើ ក្នុងរយៈពេលយោងក្នុងពេលស្រង់ទិន្នន័យជំរឿន។ សកម្មភាពសេដ្ឋកិច្ចសរុបនៅថ្នាក់ក្រោមជាតិបានកើន ៣,៣% ក្នុងរយៈពេល ១១ឆ្នាំ (២០០៨-២០១៩)។ ចំពោះបុរស ភាគរយបានកើន ៥,៩% ខ្ពស់ជាងធៀបនឹងស្ត្រីកើន ១%។

*រូបភាពទី៨៖ ស្ថានភាពសកម្មភាពសេដ្ឋកិច្ចអាយុ ៥ឆ្នាំឡើង តាមភេទ និងតំបន់កម្ពុជា ឆ្នាំ២០០៨-២០១៩*




យោងតាមលទ្ធផលជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ បានបង្ហាញថា អត្រាចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចប្រុសចាប់ផ្តើមខ្ពស់ជាងស្រីនៅគ្រប់ក្រុមអាយុបន្ទាប់ពីអាយុ ២០ឆ្នាំឡើង។ អត្រាចូលរួមសកម្មភាពសេដ្ឋកិច្ចនៅជនបទខ្ពស់ជាងទីប្រជុំជនទាំងប្រុស និងស្ត្រី អាចមកពីអត្រាចូលរួមខ្ពស់ក្នុងការងារកសិកម្មនៅជនបទ និងអត្រាចូលរួមក្នុងការសិក្សាខ្ពស់របស់កុមារនៅទីប្រជុំជន ទាំងទីប្រជុំជន និងជនបទ អត្រាចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចប្រុសខ្ពស់ជាងស្រី ដោយឡែកគម្លាតអត្រាចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចរវាងប្រុសនិងស្រី មានតិចនៅជនបទជាងទីប្រជុំជន[៤]។

*(៤) ប្រភព៖ សៀវភៅជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩*

*តារាងទី៣៖ អត្រាអ្នកចូលរួមកម្លាំងពលកម្មអាយុជាក់លាក់ (ភាគរយ) តាមក្រុមអាយុ ភេទ និងតំបន់ កម្ពុជា ឆ្នាំ២០០៨-២០១៩*

| ក្រុមអាយុ | អត្រាសកម្មភាពសេដ្ឋកិច្ច | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | សរុប | | | ទីប្រជុំជន | | | ជនបទ | | |
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) | (៩) | (១០) |
| **ឆ្នាំ២០០៨** | | | | | | | | | |
| ៥ ឆ្នាំឡើង | ៥៨,៧ | ៥៩,៣ | ៥៨,១ | ៥៣,៦ | ៥៨,៨ | ៤៩,០ | ៥៩,៤ | ៥៩,៤ | ៦០,៤ |
| ១៥ ឆ្នាំឡើង | ៧៨,៣ | ៨០,៨ | ៧៦,០ | ៦៥,៨ | ៧៣,៤ | ៥៩,១ | ៨១,៨ | ៨២,៩ | ៨០,៨ |
| ៥-១៤ | ៣,១ | ៣,០ | ៣,២ | ១,៨ | ១,៥ | ២,១ | ៣,៣ | ៣,៣ | ៣,៤ |
| ១៥-២៤ | ៦០,១ | ៥៧,១ | ៦៣,២ | ៥០,៣ | ៤៦,៤ | ៥៣,៨ | ៦៣,២ | ៦០,១ | ៦៦,៤ |
| ២៥-៥៩ | ៩១,៧ | ៩៦,៨ | ៨៧,៣ | ៧៩,៦ | ៩២,៧ | ៦៧,៦ | ៩៥,១ | ៩៨,០ | ៩២,៥ |
| ៦០ ឆ្នាំឡើង | ៦២,៦ | ៧៥,៥ | ៥៣,៧ | ៣៧,៩ | ៥៤,៧ | ២៦,៨ | ៦៧,៧ | ៧៩,៦ | ៥៩,៤ |
| **ឆ្នាំ២០១៩** | | | | | | | | | |
| ៥ ឆ្នាំឡើង | ៦២,០ | ៦៥,២ | ៥៩,០ | ៦០,៩ | ៦៦,០ | ៥៦,២ | ៦២,៨ | ៦៤,៨ | ៦០,៩ |
| ១៥ ឆ្នាំឡើង | ៧៩,១ | ៨៤,៤ | ៧៤,៣ | ៧៤,៧ | ៨១,៨ | ៦៨,១ | ៨២,២ | ៨៦,៣ | ៧៨,៦ |
| ៥-១៤ | ២,១ | ២,៥ | ១,៦ | ១,៧ | ២,០ | ១,៤ | ២,៣ | ២,៨ | ១,៨ |
| ១៥-២៤ | ៥៨,៤ | ៥៨,៩ | ៥៧,៩ | ៥៥,៨ | ៥៥,៩ | ៥៥,៧ | ៦០,៣ | ៦១,១ | ៥៩,៤ |
| ២៥-៥៩ | ៩០,៧ | ៩៦,៣ | ៨៥,៤ | ៨៦,៤ | ៩៤,៤ | ៧៨,៧ | ៩៣,៨ | ៩៧,៨ | ៩០,២ |
| ៦០ ឆ្នាំឡើង | ៦០,៧ | ៧២,៥ | ៥២,៨ | ៥២,៨ | ៦២,០ | ៣៨,៩ | ៦៧,៩ | ៧៨,៧ | ៦០,៨ |

## II. ការព្យាករណ៍ពីតម្រូវការអ្នកបច្ចេកទេសក្នុងទីផ្សារ

ទិន្នន័យដែលបានគ្រោងទុករបស់ក្រុមមុខរបរសំខាន់ៗផ្តល់ព័ត៌មានពាក់ព័ន្ធសម្រាប់វាយតម្លៃតម្រូវការបណ្តុះបណ្តាលរយៈពេល ៥ឆ្នាំខាងមុខ ដូច្នេះដើម្បីចាប់ផ្តើមវិភាគតួនាទីដែល TVET អាចដើរតួ ដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមរបស់ប្រទេស។ ចូលមកក្រុមមុខរបរសំខាន់ៗដែលមានតម្រូវការបន្ថែមជាវិជ្ជមាន យើងបានសន្មត់ថា តម្រូវការជំនួសស្មើនឹង១៥%នៃការផ្គត់ផ្គង់ដំបូង។ នេះបានអនុញ្ញាតឱ្យប៉ាន់ប្រមាណតម្រូវការការងារក្នុងមួយឆ្នាំទាក់ទងនឹងលំហូរពលកម្មប្រហែល ៤៣០ ០០០នាក់ ក្នុងមួយឆ្នាំ ដែលជាតម្លៃមួយស្រប តាមការប៉ាន់ស្មានពីមុនរបស់យើង។ ស្ទើរតែ ៥៧% នៃអ្នកចូលក្នុងវិស័យការងារត្រូវបានទាក់ទងទៅនឹងក្រុមមុខរបរសិប្បកម្ម និងមុខរបរដែលពាក់ព័ន្ធ ហើយ ១៤% សម្រាប់កម្មករបម្រើផ្នែកសេវាកម្ម និងការលក់ និង ១៣% សម្រាប់បុគ្គលិកការិយាល័យ។ ដូច្នេះក្រុមការងារទាំង ៣ នេះត្រូវបានគេគ្រោងនឹងស្រូបយក ៣/៤ នៃចំនួនសរុប និង ១៥% ទៀតនឹងមាននៅក្នុងរោងចក្រ និងអ្នកបញ្ជាម៉ាស៊ីនមាន ៦.៣% អ្នកជំនាញមាន ៥.៧% និងអ្នកបច្ចេកទេសមាន ៣.៩%។

*តារាងទី៤៖ ចំនួនអ្នកដែលចូលក្នុងវិស័យការងារតាមមុខរបរសំខាន់ៗ តម្លៃដាច់ខាត (គិតជាពាន់) និងសមាសភាពជា% ឆ្នាំ២០១៧-២០២២*

| | Yearly labor in terms of flowdemand | |
|---|---|---|
| | Absolute value | % comp. |
| Craft and related worker | 244 | 56.7 |
| Service and sales workers | 62 | 14.4 |
| Clerical support workers | 56 | 13.0 |
| Plant and machine operators and assemblers | 27 | 6.3 |
| Professionals | 24 | 5.7 |
| Technicians and associate professionals | 17 | 3.9 |
| Total civil sector | 430 | 100.0 |

ក្នុងរយៈពេល ៥ឆ្នាំខាងមុខ តម្រូវការកម្លាំងពលកម្មប្រហែល ៥៧% ទាក់ទងនឹងលំហូរត្រូវឆ្ពោះទៅរកមុខរបរដែលត្រូវបានចាត់ចូលក្នុងក្រុមមុខរបរសំខាន់ៗ "សិប្បកម្ម និងមុខរបរដែលពាក់ព័ន្ធ"។ នៅលើមូលដ្ឋាននៃព័ត៌មានផ្សេងទៀត យើងក៏អាចបង្ហាញផងដែរថា មុខរបររបស់ក្រុមនេះនឹងដើរតួនាទីសំខាន់បំផុតគឺ៖ ១) មុខរបរនៃវិស័យសំណង់ និង ២) មុខរបរនៃវិស័យកាត់ដេរ។ ទិន្នន័យកន្លងមកបានបង្ហាញឱ្យឃើញថា តម្រូវការតម្លាំងពលកម្មប្រចាំឆ្នាំមានប្រមាណ ១០០ ០០០នាក់ ដែលបានទទួលការបណ្តុះបណ្តាលជំនាញក្នុងកម្រិតខុសៗគ្នា និងអាចនិយាយបានថា ប្រមាណជា ៨០ ០០០នាក់បន្ទាប់ទៀត។ ក្នុងករណីទាំងពីរទំហំនៃតម្រូវការនឹងត្រូវការអ្នកស្វែងរកការងារ និងកម្មករដំបូងមកពីវិស័យកសិកម្ម។ នេះបញ្ជាក់ពីតម្រូវការនៃវគ្គបណ្តុះបណ្តាល និងការបណ្តុះបណ្តាលម្តងទៀត។

ដើម្បីបញ្ជាក់ពីមុខរបរដែលការបណ្តុះបណ្តាលវិជ្ជាជីវៈជាចាំបាច់ យើងអាចចាំបានថា សន្ទស្សន៍ចក្ខុវិស័យការងារឆ្នាំ២០១៨ (Job outlook Index-JOI) របស់ NEA បានប៉ាន់ប្រមាណថាអ្នកមើលការខុសត្រូវសំណង់ ជាងតបណ្តាញទឹក និងបំពង់បង្ហូរទឹក ជាងផ្សារដែក ជាងលាបថ្នាំ កម្មករសំណង់នឹងស្ថិតនៅចន្លោះការងារដែលមានកង្វះខាតការផ្គត់ផ្គង់។ លើសពីនេះទៅទៀត និន្នាការវិជ្ជមាននៃវិស័យសំណង់នឹងជះឥទ្ធិពលជាវិជ្ជមានដល់តម្រូវការការងាររបស់កម្មករជំនាញពាណិជ្ជកម្មផ្សេងទៀតដូចជា ជាងឈើ កម្មករបេតុង កម្មករសំណង់ និងជាងអគ្គិសនីដែលពាក់ព័ន្ធ និងជាងបៀកថ្នាំ។ នៅចុងបញ្ចប់សន្ទស្សន៍ NEA បានបង្ហាញថា វិស្វករសំណង់ស៊ីវិល ស្ថាប័ត្យករ អ្នករៀបឥដ្ឋ និងជាងដំបូលត្រូវបានគេរំពឹងថា នឹងមានឱកាសមធ្យមដើម្បីធ្វើការ។

ចូលមកវិស័យកាត់ដេរ (យោងទៅតាមធនាគារពិភពលោកផ្តល់ការងារដល់ប្រជាជន ១លាននាក់) យើងអាចផ្តល់យោបល់ថា តម្រូវការនឹងត្រូវបានប្រកាសបន្ថែមទៀតដែលបានស្នើឡើងនៅពេលដែលតម្រូវការជំនួសត្រូវបានគេយកមកពិចារណា ហើយដែលថា មុខរបរមួយចំនួនដូចជា ផ្នែកវាយនភ័ណ្ឌ ផលិតអាវរោមសត្វ បោកគក់ និងអ្នកបញ្ជាម៉ាស៊ីនសម្រាប់ផលិតផលស្បែក និងកាត់ដេរស្បែកជើង វាយនភ័ណ្ឌ

និងអ្នកធ្វើការផ្នែកអាជីវកម្មដែលពាក់ព័ន្ធ អ្នកច្នៃម៉ូដសម្លៀកបំពាក់ ប៉ុន្តែក៏ជាអ្នកមើលការខុសត្រូវផលិតកម្ម បុគ្គលិកផ្នែកវេចខ្ចប់ផលិតកម្ម និងអ្នកបញ្ជាម៉ាស៊ីនដាក់ស្លាក ម៉ាស៊ីនវេចខ្ចប់ កម្មករខ្ចប់ផលិតផលដោយដៃ កម្មកររោងចក្រនឹងត្រូវបានស្នើសុំយ៉ាងខ្លាំង។ ពួកគេទាំងអស់នឹងត្រូវការការបណ្តុះបណ្តាលវិជ្ជាជីវៈ។

ការព្យាករណ៍របស់យើងគឺតម្រូវការកម្លាំងពលកម្មទាក់ទងនឹងលំហូរសម្រាប់អ្នកលក់ និងបុគ្គលិកសេវាកម្មនឹងមានចំនួនច្រើនជាង ៦០ ០០០នាក់ ក្នុងមួយឆ្នាំ។ ដោយពិចារណាលើទីផ្សារការងារនៅប្រទេសកម្ពុជា តំបន់មុខរបរដែលពាក់ព័ន្ធបំផុត គឺតំបន់ដែលជាប់ទាក់ទងនឹងវិស័យទេសចរណ៍ (កំណត់យ៉ាងទូលំទូលាយ) និងពាណិជ្ជកម្មលក់រាយ។

នៅក្នុងវិស័យទេសចរណ៍ ជាវិស័យដើរតួនាទីសំខាន់បំផុតទាក់ទងនឹងទំហំនៃតម្រូវការនឹងត្រូវបានដើរតួនាទីដោយមុខរបរដែលទាក់ទងនឹងការស្នាក់នៅ និងភោជនីយដ្ឋាន ហើយជាពិសេសជាងនេះទៀត ដោយអ្នកសម្អាត និងកូនកាំបិត អ្នកជំនួយការផ្ទះបាយ អ្នកបម្រើនៅតាមភោជនីយដ្ឋាន អ្នករៀបចំអាហារចម្អិនស្រាប់ (Fast-Food) អ្នកចម្អិនអាហារ អ្នកទទួលភ្ញៀវ។ បន្ទាប់មក NEA JOI ណែនាំថា ទោះបីជាតម្រូវការទាក់ទងនឹងទំហំមានតិចតួចក៏ដោយ ក៏ជាឱកាសការងារល្អបំផុតសម្រាប់មេចុងភៅ អ្នកក្រឡុកស្រា និងអ្នកគ្រប់គ្រងសណ្ឋាគារ និងភោជនីយដ្ឋាន។

នៅក្នុងវិស័យពាណិជ្ជកម្ម តម្រូវការដ៏ធំបំផុតនឹងត្រូវបានតម្រង់ទិសដៅទៅរកមុខរបរដែលត្រូវការជំនាញកម្រិតទាបដូចជា អ្នកលក់តាមហាង តូប និងអ្នកលក់អាហារតាមផ្លូវ ខណៈដែលមិនសូវមានការងារធ្វើ ប៉ុន្តែគួរឱ្យចាប់អារម្មណ៍ដែលឱកាសការងារនឹងមានសម្រាប់អ្នកគ្រប់គ្រងហាង បេឡាករ អ្នកគ្រប់គ្រងផ្នែកលក់ និងទីផ្សារ អ្នកបង្ហាញលក់ផលិតផល និងអ្នកលក់ផលិតផលបច្ចេកវិទ្យាព័ត៌មានវិទ្យា។ វិស័យព័ត៌មានវិទ្យា នឹងត្រូវការអ្នកឯកទេស និងអ្នកបច្ចេកទេសជាច្រើនដូចជា អ្នកបច្ចេកទេសគាំទ្រអ្នកប្រើបច្ចេកវិទ្យាព័ត៌មានវិទ្យា អ្នកវិភាគប្រព័ន្ធ និងស្ថាបត្យករបច្ចេកវិទ្យា អ្នកបង្កើតកម្មវិធី អ្នកបង្កើតប្រព័ន្ធអ្នកបច្ចេកទេសប្រតិបត្តិការបច្ចេកវិទ្យាព័ត៌មានវិទ្យា អ្នកជំនាញទិន្នន័យ និងតបណ្តាញ អ្នកបណ្តុះបណ្តាលបច្ចេកវិទ្យាព័ត៌មាន តបណ្តាញកុំព្យូទ័រ និងអ្នកបច្ចេកទេសតប្រព័ន្ធ។ ហើយសហគ្រាសគ្រប់វិស័យត្រូវការគណនេយ្យករ និងអ្នកជំនាញផ្នែកទីផ្សារ។ សូមបញ្ជាក់ថាយោងតាម NEA JOI មុខរបរទាំងអស់នេះ គឺខ្វះខាតដូច្នេះហើយ ត្រូវការការបណ្តុះបណ្តាល។ តារាងខាងក្រោមសង្ខេបការប៉ាន់ប្រមាណរបស់យើង អំពីតម្រូវការទាក់ទងនឹងលំហូរសម្រាប់មុខរបរម៉ាក្រូ ហើយសម្រាប់មុខរបរម៉ាក្រូនីមួយៗមាន ១) បញ្ជីមុខរបរដែលការបណ្តុះបណ្តាលត្រូវបានផ្តល់អនុសាសន៍យ៉ាងខ្លាំងដោយសារតែកង្វះការផ្គត់ផ្គង់កម្លាំងពលកម្មដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និង ២) មុខរបរផ្សេងទៀតដែលការបណ្តុះបណ្តាលអាចដើរតួនាទីយ៉ាងសំខាន់ក្នុងការអនុគ្រោះដល់លទ្ធភាពទទួលបានការងារ(៥)។

---

(៥) *ប្រភព៖ សៀវភៅព្យាករណ៍ទីផ្សារកម្លាំងពលកម្មនៅកម្ពុជាឆ្នាំ២០១៧-២០២៧ ក្រោមគម្រោងអភិវឌ្ឍន៍វិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVETSDP)*

*តារាងទី៥៖ តម្រូវការកម្លាំងពលកម្មជាមធ្យមប្រចាំឆ្នាំក្នុងលក្ខខណ្ឌលំហូរ* **Macro-occupations** *(ឆ្នាំ២០១៨-២០២២) បញ្ជីមុខរបរសម្រាប់វគ្គបណ្តុះបណ្តាលដែលត្រូវការ ដើម្បីប្រឈមនឹងកង្វះនៃការផ្គត់ផ្គង់បុគ្គលដែលមានគុណវុឌ្ឍិ និងបញ្ជីមុខរបរដែលបានផ្តល់អនុសាសន៍ដើម្បីធ្វើការបណ្តុះបណ្តាល។*

| | Average yearly Labour demand in terms of flow | Occupations for which labour supply is insufficent and training necessary | Occupations for which the supply is in line with demand but training would provide an important plus |
|---|---|---|---|
| **Craft and related workers** | **244,000** | | |
| *Cccupations of the construction sector* | *100,000* | Construction supervisors, Plumbers and Pipe fitters, Glaziers, Welders, Painters, Building construction laborers | Civil engineers, Architects, Civil engineering technicians, Bricklayers, Roofers, Concrete workers, building and related electricians, plasterers. |
| *Occupations of the garment sector* | *80,000* | Manufacturing supervisors, Garment designer, Production clerk; Fur and leather products machine operator; Footwear, textile and related trades workers; Packing and labelling machine operators, Hand packers, Manufacturing laborers | |
| *Other Occupations* | *64,000* | Wood workers; food workers | |
| **Service and sales workers** | **62,000** | | |
| *Tourism* | *32,000* | Chefs, Bartenders, and Hotel and restaurant managers. | Receptionists, Cooks, Kitchen helpers, Waiters, Fast food preparers, Cleaners and helpers |
| *Retail trade* | *30,000* | Shop supervisors, Cashiers, Sales and marketing managers, Sale demonstrators and ICT sale persons | salespersons for shops, stalls, and street-food shops |
| **Clerical support workers** | **56,000** | Administrative and executive secretaries; Office clerks; Bank tellers, Bank clerks, Contact centre information clerks, | |
| **Agriculture, forestry and fishery** | **40,000** | Agricultre engineer, Soil and plant specialist, Agriculture food scientist, Agronomist, Horticulture technician, Hydraiulics technician, Wildlife and forestry management and conservation, Fisheries bilogist, Fisheries manager, | |
| **Plant and machine operators and assemblers** | **27,000** | Industrial and production engineers, Mechanical engineers; Steam engine and boiler operators, Mechanical machinery assemblers, Machinery mechanics and repairers, Heavy truck and lorry drivers. | |
| **Technicians and professionals** | **41,000** | | |
| *Health sector* | | Radiographers, Medical and pathology laboratory technician, Dental assistant, Midwifes | |
| *Tourism* | | Translators and interpreters; Accountants and marketing professionals. | |
| *IT sector* | | ICT user support technicians, System analysts and IT architects, Software and system developers, ICT operations technicians, Database and network professionals, Information technology trainers, Computer network and systems technicians | |

# III. ការបណ្តុះបណ្តាលជំនាញក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

បច្ចុប្បន្ន ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានគ្រឹះស្ថានសិក្សាក្រោមឱវាទចំនួន ១១០ ក្នុងនោះ គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈសាធារណៈ ចំនួន ៣៨ គ្រឹះស្ថានសិក្សាឯកជន ចំនួន ៤៧ និងអង្គការ សមាគម ចំនួន ២៥។ គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈសាធារណៈ បាននិងកំពុងផ្តល់ការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ នៅគ្រប់កម្រិតសិក្សា លើវគ្គសិក្សារយៈពេលខ្លី និងរយៈពេលវែង (ក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ) សិក្សាចល័ត និងកម្មវិធីបង្រៀន និងរៀនពីចម្ងាយ ឬតាមអនឡាញ លើជំនាញជាច្រើនដូចជា៖ សំណង់ស៊ីវិល អគ្គិសនី អេឡិចត្រូនិច បរិក្ខារត្រជាក់ មេកានិក យន្តសាស្ត្ររថយន្ត កម្មន្តសាល ធុរៈកិច្ច/ICT សហគ្រិនភាព ទេសចរណ៍ និងបដិសណ្ឋារកិច្ច តបណ្តាញទឹក តបណ្តាញអគ្គិសនីក្នុងអគារ លោហៈបន្ទះផ្សារ ក្រឡឹង ជួសជុលម៉ាស៊ីនគ្រប់ធន់ សេវាកម្មរដ្ឋបាល សេវាកម្មកុំព្យូទ័រ កាត់កញ្ចក់វ៉ែនតា (អុបទិក) កសិកម្ម និងកែច្នៃបន្លែផ្លែឈើ វិជ្ជាធ្វើម្ហូប ឆុងកាហ្វេ និងភេសជ្ជៈ ក្រឡុកស្រា កាត់ដេរសម្លៀកបំពាក់ សម្អាងការ និងសម្អាងកាយ និងជំនាញវិជ្ជាជីវៈជាច្រើនទៀត[៦]។

[៦] *ប្រភព៖ សៀវភៅព័ត៌មានទូទៅរបស់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០១៩*

## ១-លំហូរនៃការចូលរៀនក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

តាមលទ្ធផលចុងក្រោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ បានបង្ហាញថា អត្រាអក្ខរភាពសម្រាប់ភាសាណាមួយក្នុងចំណោមប្រជាជនកម្ពុជា អាយុ ៧ឆ្នាំឡើង អត្រាអក្ខរភាពរបស់ស្ត្រីបានកើនឡើងប្រមាណ ១៣,១% បើធៀបទៅនឹងការកើនឡើងប្រមាណ ៧,១% សម្រាប់បុរស។ ទោះយ៉ាងណាក៏ដោយ គម្លាតដ៏ធំរវាងអក្ខរភាពបុរស និងស្ត្រី (៩១,១% សម្រាប់បុរស និង ៨៦,២% សម្រាប់ស្ត្រី ឆ្នាំ២០១៩) ខ្ពស់នៅជនបទ។ ជាទូទៅ វិសាលភាពរវាងបុរស និងស្ត្រី លើការអប់រំជាមូលដ្ឋាន គឺជាបញ្ហាចម្បងមួយរបស់រាជរដ្ឋាភិបាលដែលត្រូវពិចារណាជាបន្ទាន់[៧]។

[៧] *ប្រភព៖ សៀវភៅជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩*

*រូបភាពទី៩៖ ភាគរយអក្ខរភាពអាយុ ៧ឆ្នាំឡើង តាមភេទ កម្ពុជា ឆ្នាំ២០០៨-២០១៩*



យោងតាមរបាយការណ៍របស់នាយកដ្ឋាន ព័ត៌មានទីផ្សារការងារ (ទិន្នន័យ TVETMIS) គិតចាប់តាំងពីឆ្នាំសិក្សា ២០០៥-២០០៦ រហូតមកដល់ឆ្នាំសិក្សា ២០១៩-២០២០ មានសិក្ខាកាម សិស្ស និស្សិត បានបញ្ចប់ការសិក្សានៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈសាធារណៈ ឯកជន និងអង្គការ សមាគម សរុបចំនួន ៩៥២ ០២១នាក់ ស្រី ៤៨៣ ៩៧២នាក់ ក្នុងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈសាធារណៈ សរុបចំនួន ៨០៣ ២២៩នាក់ ស្រី ៤១៤ ៩១២នាក់ គ្រឹះស្ថានសិក្សាឯកជន សរុបចំនួន ៩១ ១៧៦នាក់ ស្រី ៤២ ១៥៦នាក់ និងអង្គការ សមាគម សរុបចំនួន ៥៧ ៦១៦នាក់ ស្រី ២៦ ៩០៤នាក់។ គិតត្រឹម ៥ឆ្នាំ ចុងក្រោយនេះ (ឆ្នាំសិក្សា ២០១៥-២០១៦ ដល់ឆ្នាំសិក្សា ២០១៩-២០២០) មានសិក្ខាកាម សិស្ស និស្សិត បានបញ្ចប់ការសិក្សានៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈសាធារណៈ ឯកជន និងអង្គការ សមាគម សរុបចំនួន ២៣៥ ៩៣៤នាក់ ស្រី ១០៨ ៥៤៦នាក់។

*រូបភាពទី១០៖ ស្ថិតិសិក្ខាកាម សិស្ស និស្សិត បញ្ចប់ការសិក្សាពីឆ្នាំ២០០៥-២០២០*




*រូបភាពទី១១៖ ស្ថិតិសិក្ខាកាម សិស្ស និស្សិត បញ្ចប់ការសិក្សាពីឆ្នាំ២០០៥-២០២០ របស់គ្រឹះស្ថាន អ.ប.វ. សាធារណៈ*



## ២-ស្ថិតិសិក្ខាកាម សិស្ស និស្សិតសិក្សាតាមជំនាញអាទិភាព ២០១៩-២០២០

អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ បានធ្វើការស្រាវជ្រាវ និងរៀបចំកំណត់ ឈ្មោះ លេខកូដ ចំណងជើងមុខរបរ និងកម្រិតគុណវុឌ្ឍិ នៅក្នុងវិស័យអាទិភាព ចំនួន ៦ ស្មើនឹង ៤១មុខរបរ ក្នុងនោះ (១)-វិស័យសំណង់ មានចំនួន ១១មុខរបរ (២)-វិស័យមេកានិក មានចំនួន ១០មុខរបរ (៣)-វិស័យអគ្គិសនី និងថាមពល មានចំនួន ៣មុខរបរ (៤)-វិស័យធុរកិច្ច/ICT មានចំនួន ៨មុខរបរ (៥)-វិស័យកម្មន្តសាល មានចំនួន ៧មុខរបរ និង (៦)-វិស័យបរិក្ខារត្រជាក់ និងកម្តៅ មានចំនួន ២មុខរបរ។ គិតពីឆ្នាំ២០១៤ ដល់ឆ្នាំ២០២០ មានសិក្ខាកាម សិស្ស និស្សិត បានបញ្ចប់ការសិក្សាទៅតាមវិស័យទាំង៦ បានសរុបចំនួន ៥៤ ៨០៤នាក់ ស្រី ១៣ ៧៣៨នាក់[៨]។

[៨] *ប្រភព៖ ស្ថិតិនាយកដ្ឋានព័ត៌មានទីផ្សារការងារ-TVETMIS*

*រូបភាពទី១២៖ ស្ថិតិសិក្ខាកាម សិស្ស និស្សិតតាមវិស័យឆ្នាំសិក្សា ២០១៤-២០២០*




## ៣-កម្មវិធីបង្រៀន និងរៀនពីចម្ងាយ ឬតាមអនឡាញ



*ឯកឧត្តមបណ្ឌិត **ពេជ សោភ័ន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការប្រចាំការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាប្រធានគណៈកម្មការគ្រប់គ្រង និងដឹកនាំរៀបចំប្រព័ន្ធបណ្តុះបណ្តាលពីចម្ងាយ ឬតាមអនឡាញ*

ស្ថិតក្នុងបរិបទនៃរាតត្បាតជាសកលជំងឺកូវីដ-១៩ បង្កឱ្យមានផលប៉ះពាល់អវិជ្ជមានមកលើបញ្ហាសុខភាពសាធារណៈ សេដ្ឋកិច្ច សង្គម ការអប់រំនិងបណ្តុះបណ្តាល និងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ការបាត់បង់ការងារជាច្រើន ហើយថែមទាំងបន្ទុចបង្អាក់

ដល់ការអភិវឌ្ឍឈានឡើងរបស់កម្ពុជាផងដែរ។ គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៅទូទាំងប្រទេស ទាំងសាធារណៈ ឯកជន និងអង្គការ សមាគម ត្រូវបានផ្អាកដំណើរការសិក្សា និងសកម្មភាពនានាជាបន្តបន្ទាប់។ ដើម្បីធានានិរន្តរភាពនៃការបង្រៀន និងរៀនរបស់សាស្ត្រាចារ្យ គ្រូបច្ចេកទេស និងសិក្ខាកាម សិស្ស និស្សិត ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដាក់ចេញនូវគោលការណ៍ណែនាំស្តីពីការបង្រៀន និងរៀនពីចម្ងាយ ឬតាមអនឡាញសម្រាប់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងបាននិងកំពុងដាក់ឱ្យដំណើរការប្រព័ន្ធជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈពីចម្ងាយ ឬតាមអនឡាញ ព្រមទាំងបំពាក់មូលដ្ឋានសម្ភារ ឧបករណ៍បច្ចេកវិទ្យាព័ត៌មាន ក៏ដូចជាការអភិវឌ្ឍ និងកែលម្អកម្មវិធីសិក្សា និងបំប៉នសមត្ថភាពគ្រូបច្ចេកទេសនូវវិធីសាស្ត្របង្រៀនបែបគន្លងថ្មី។ កម្មវិធីបង្រៀន និងរៀនពីចម្ងាយ ឬតាមអនឡាញ សិក្ខាកាម សិស្ស និស្សិត អាចប្រើប្រាស់បានទាំង Computer, I pad, Tablet, Smart phone ជាមួយនឹងកម្មវិធី App Store, Google Play, AppGallery ។

នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញសេចក្តីសម្រេចលេខ ០៤៩/២០ ក.ប/ស.ស.រ.អ.ប.វ ស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រង និងដឹកនាំរៀបចំប្រព័ន្ធបណ្តុះបណ្តាលពីចម្ងាយ ឬតាមអនឡាញ សម្រាប់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក្រោមឱវាទក្រសួងដោយមាន **ឯកឧត្តមបណ្ឌិត ពេជ សោភ័ន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការប្រចាំការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាប្រធានគណៈកម្មការ។ គណៈកម្មការ



TVET E-Learning App

គ្រប់គ្រង និងដឹកនាំរៀបចំប្រព័ន្ធបណ្តុះបណ្តាលពីចម្ងាយ ឬតាមអនឡាញ មានគោលបំណងបង្កើតប្រព័ន្ធអប់រំបណ្តុះបណ្តាលពីចម្ងាយ ឬតាមអនឡាញ និងកម្មវិធីបណ្តុះបណ្តាលតាមជំនាញនិងកម្រិតសិក្សាសម្រាប់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក្រោមឱវាទក្រសួង ដើម្បីធានានិរន្តរភាពនៃការបង្រៀន និងរៀនរបស់សាស្ត្រាចារ្យ គ្រូបច្ចេកទេស និងសិក្ខាកាម សិស្ស និស្សិតក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក្នុងបរិបទជំងឺកូវីដ-១៩ និងការជំរុញការសិក្សាតាមសម័យបច្ចេកវិទ្យាឌីជីថលក្នុងដំណាក់កាលនៃបដិវត្តឧស្សាហកម្មទី៤។

សម្រាប់ឆ្នាំសិក្សា ២០២០-២០២១ នេះ គិតត្រឹមឆមាសទី១ ឆ្នាំ២០២១ មានសិក្ខាកាម សិស្ស និស្សិត ប្រមាណ ៤៦ ៤១៣នាក់ ស្រី ១៥ ៦៦៥នាក់ បាននិងកំពុងសិក្សាពីចម្ងាយ ឬតាមអនឡាញ នៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ទាំងសាធារណៈ ឯកជន និងអង្គការ សមាគមទូទាំងប្រទេស[៩]។

---

(៩) *ប្រភព៖ ស្ថិតិនាយកដ្ឋានព័ត៌មានទីផ្សារការងារ-TVETMIS*

## ៤-កម្មវិធីបណ្តុះបណ្តាលកម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ១ (C1) វគ្គពិសេសជូនកម្មករនិយោជិត

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំឱ្យមានវគ្គបណ្តុះបណ្តាលពិសេសមួយដែលមានភាពបត់បែន និងផ្តោតលើគុណភាពក្រោយពេលបញ្ចប់ការសិក្សាលើកម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ១ (C1) វគ្គពិសេស ជូនដល់កម្មករនិយោជិតដែលកំពុងត្រូវបានព្យួរកិច្ចសន្យាការងារ ឬបាត់បង់ការងារដោយសារវិបត្តិជំងឺកូវីដ-១៩ ដែលមានរយៈពេល ៤ខែ ក្នុងជំហានទី១ មានសិក្ខាកាមសរុបចំនួន ៦ ៥០០នាក់ ស្រី ៣ ៤៩៧នាក់ ព្រមទាំងបានផ្តល់នូវប្រាក់ឧបត្ថម្ភក្នុងអំឡុងពេលសិក្សាដោយសិក្ខាកាមម្នាក់ទទួលបាន ២០ម៉ឺនរៀលក្នុង ១ខែ ដើម្បីផ្តល់ឱកាសឱ្យពួកគាត់ទទួលបាននូវជំនាញមួយច្បាស់លាស់ សម្រាប់ចាប់យកការងារថ្មីនៅក្នុងទីផ្សារការងារដែលកំពុងមានតម្រូវការខ្ពស់នាពេលបច្ចុប្បន្ន និងទៅអនាគត ហើយអាចប្រកបមុខរបរដោយខ្លួនឯង។ វគ្គបណ្តុះបណ្តាលបច្ចេកទេសនេះ បានផ្តោតទៅលើរាជធានី ខេត្តគោលដៅចំនួន ៧ រួមមាន រាជធានីភ្នំពេញ ខេត្តស្វាយរៀង ព្រះសីហនុ សៀមរាប កណ្តាល កំពង់ចាម និងខេត្តកំពង់ឆ្នាំង ដែលមានជំនាញអាទិភាពដូចជា តបណ្តាញអគ្គិសនី ជួសជុលថែទាំបរិក្ខារអគ្គិសនី រចនាក្រាហ្វិកដោយកុំព្យូទ័រនិងបោះពុម្ព ជួសជុលបរិក្ខារអេឡិចត្រូនិច តបណ្តាញទឹក ជួសជុលនិងថែទាំរថយន្ត ជួសជុលនិងថែទាំអគ្គិសនីរថយន្ត ជួសជុលនិងថែទាំម៉ាស៊ីនត្រជាក់រថយន្ត, ជួសជុលនិងថែទាំម៉ាស៊ីនធុនតូច, ថែទាំបរិក្ខារត្រជាក់ក្នុងគេហដ្ឋាន, ផ្សារអគ្គិសនី, សេវាកម្មគ្រប់គ្រងយានដ្ឋាន បច្ចេកទេសកែច្នៃគ្រឿងបន្លាស់ម៉ាស៊ីន ជំនាញធ្វើម្ហូបខ្មែរ ជំនាញធ្វើម្ហូបថៃ ជំនាញឆុងកាហ្វេនិងភេសជ្ជៈ, ជំនាញដុតនំប៉័ង ជំនាញក្រឡុកស្រា ការកែច្នៃបន្លែនិងផ្លែឈើ ធុរកិច្ចទេសចរណ៍ និងសហគ្រិនភាព អ្នកគ្រប់គ្រងផ្នែកភោជនីយដ្ឋាននិងក្រមសីលធម៌វិជ្ជាជីវៈ អ្នកគ្រប់គ្រងការិយាល័យជួរមុខនិងក្រមសីលធម៌វិជ្ជាជីវៈ អ្នកគ្រប់គ្រងគេហកិច្ច និងក្រមសីលធម៌វិជ្ជាជីវៈ និងកែសម្ផស្ស សម្អាង និងសាឡន[90]។

[90] *ប្រភព៖ នាយកដ្ឋានបណ្តុះបណ្តាល*

*រូបភាពទី១៣៖ សិក្ខាកាមទទួលបានការបណ្តុះបណ្តាល C1 វគ្គពិសេស*



## ៥-និមិត្តសញ្ញា អ.ប.វ. (TVET Cambodia)

ដើម្បីជំរុញ និងបង្កើនការផ្សព្វផ្សាយអំពីវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៅកម្ពុជា ឱ្យបានកាន់តែមានប្រសិទ្ធភាពខ្ពស់ និងទូលំទូលាយទៅដល់គ្រប់ទីកន្លែងទាំងក្នុង និងក្រៅប្រទេស នាយកដ្ឋានព័ត៌មានទីផ្សារការងារ នៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ បានរៀបចំរចនានិមិត្តសញ្ញា TVET សម្រាប់ប្រើប្រាស់សម្គាល់ជាផ្លូវការ ក្នុងគោលបំណងផ្សព្វផ្សាយដល់សិស្ស និស្សិត យុវជន និងសាធារណជន គ្រឹះស្ថានសិក្សា ផ្នែកឯកជន ដៃគូអភិវឌ្ឍន៍ និងអង្គភាពពាក់ព័ន្ធនានាបានយល់ដឹងកាន់តែច្បាស់ពីសារៈសំខាន់នៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៅកម្ពុជា។

ខាងក្រោមនេះ ជានិមិត្តសញ្ញា និងអត្ថន័យរបស់និមិត្តសញ្ញា អ.ប.វ. (TVET Cambodia)៖

**១. រង្វង់ស្លឹកចំនួន ៨** ៖ តំណាងឱ្យការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ស្របតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជាដែលមាន ៨កម្រិត

**២. រង្វង់កង** ៖ តំណាងឱ្យការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ផ្តល់ជូនដល់ប្រជាពលរដ្ឋគ្រប់រូប និងគ្រប់ទីកន្លែងទូទាំងប្រទេសកម្ពុជា

**៣.ផ្ការំដួល** ៖ តំណាងឱ្យស្ត្រីក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

**៤. ពណ៌ខៀវ** ៖ តំណាងឱ្យភាពបត់បែននៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ លើគ្រប់កម្មវិធីបណ្តុះបណ្តាល

**៥. ពណ៌ស** ៖ តំណាងឱ្យការបណ្តុះបណ្តាលជំនាញទន់ ដែលសំដៅទៅលើភាពទន់ភ្លន់ ការទទួលខុសត្រូវ ការងារជាក្រុម ភាពជឿជាក់ ភាពស្មោះត្រង់ និងសីលធម៌វិជ្ជាជីវៈការងារ

**៦. TVET** ៖ (Technical Vocational Education and Training) តំណាងឱ្យការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅកម្ពុជា

**៧. កម្ពុជា-Cambodia** ៖ តំណាងឱ្យព្រះរាជាណាចក្រកម្ពុជា

**៨. រូបក្ងួរស្រូវ** ៖ តំណាងឱ្យការសាមគ្គី កិច្ចសហការគ្រប់ភាគីពាក់ព័ន្ធមកលើ TVET ក្នុងការបណ្តុះគ្រាប់ពូជ (ធនធានអ្នកបច្ចេកទេស) សម្រាប់បំពេញតម្រូវការនៅលើទីផ្សារការងារក្នុងស្រុក និងក្រៅស្រុក។

# ឯកសារយោង

- នាយកដ្ឋានព័ត៌មានទីផ្សារការងារ (ទិន្នន័យ TVETMIS) នៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- សៀវភៅព័ត៌មានទូទៅរបស់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០១៩
- សៀវភៅជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩
- សៀវភៅព្យាករណ៍ទីផ្សារកម្លាំងពលកម្មនៅកម្ពុជាឆ្នាំ២០១៧-២០២៧ ក្រោមគម្រោងអភិវឌ្ឍន៍វិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVETSDP)

# TVET

# ជំនាញពិត ជីវិតប្រសើរ!

រក្សាសិទ្ធិដោយ៖

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ**

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ

ទំនាក់ទំនង៖ ០១៧ ៧៤៧ ៧៧៣/០១០ ៣០៦ ៨៥៥ ទំព័រហ្វេសប៊ុក៖ ១-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២-TVET-News